**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកំពង់ចាម**
លេខ..០០៧/២១..សណ

# សេចក្តីណែនាំ
## ស្តីពី
## ការបន្តអនុវត្តនូវវិធានការរដ្ឋបាល និងការផ្អាកទីតាំងរមណីយដ្ឋានទេសចរណ៍ធម្មជាតិ កែច្នៃ ដេប៉ូលក់ចែកចាយស្រាបៀរគ្រប់ប្រភេទ ការលក់ដូរ និងការទទួលទានគ្រឿងស្រវឹងគ្រប់ប្រភេទ ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ រយៈពេល០២(ពីរ)សប្តាហ៍ ចាប់ពីថ្ងៃទី២១ ខែមេសា ដល់ថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០២១ នៅក្នុងភូមិសាស្ត្រខេត្តកំពង់ចាម

យោងអនុក្រឹត្យលេខ៥៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត, សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជា លេខ ៥១សសរ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១ ស្តីពីការបន្តហាមឃាត់ការធ្វើដំណើរ និងបិទរមណីយដ្ឋានទេសចរណ៍នៅទូទាំងប្រទេសជាបណ្តោះអាសន្ន ដើម្បីទប់ស្កាត់ ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងលិខិតបទដ្ឋានគតិយុត្តិដែលមានជាធរមាន។

ដើម្បីចូលរួមក្នុងការទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ កាត់ផ្តាច់ខ្សែចម្លងពីសហគមន៍មួយទៅសហគមន៍មួយ និងដោយផ្អែកលើស្ថានភាពនៃការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍សហគមន៍ ២០-កុម្ភៈ នៅមិនទាន់មានភាពធូរស្រាលនៅឡើយ។ ជាមួយគ្នានេះ ដើម្បីធានាការពារអាយុជីវិតរបស់បងប្អូន ប្រជាពលរដ្ឋ សុខភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ និងដើម្បីកាត់បន្ថយឱ្យបានជាអតិបរមានូវផលប៉ះពាល់នៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។ រដ្ឋបាលខេត្តកំពង់ចាម សម្រេចបន្តផ្អាកជាបណ្តោះអាសន្នរយៈពេល០២ (ពីរ) សប្តាហ៍ ចាប់ពីថ្ងៃទី២១ ខែមេសា ដល់ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២១ នូវទីតាំងរមណីយដ្ឋានទេសចរណ៍ធម្មជាតិ កែច្នៃ ដេប៉ូចែកចាយស្រាបៀរគ្រប់ប្រភេទ ការលក់ដូរ និងការទទួលទានគ្រឿងស្រវឹងគ្រប់ប្រភេទ និងសកម្មភាពអាជីវកម្មពេលរាត្រី រួមមាន៖ ភោជនីយដ្ឋាន អាហារដ្ឋាន គូបលក់ចល័ត ផ្សារទំនើប ម៉ាត ទីសាធារណៈនានាដែលមានសភាពអ៊ូអរ និងមានមនុស្សជួបជុំក្នុងចំនួនច្រើនជាដើម។

រដ្ឋបាលខេត្តកំពង់ចាម សង្កេតឃើញថានៅក្នុងអំឡុងពេលដែលរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋបាលខេត្ត បានធ្វើការណែនាំ ហាមឃាត់ការប្រមូលផ្តុំជួបជុំទទួលទានគ្រឿងស្រវឹង និងប្រមូលផ្តុំជួបជុំគ្នាលេងល្បែងផ្សេងៗទៀត ក៏នៅមានបងប្អូនមួយចំនួនតូចនៅតែបំពានការហាមឃាត់នេះ ហេតុនេះ រដ្ឋបាលខេត្តកំពង់ចាម សូមធ្វើការណែនាំដល់រដ្ឋបាលក្រុង-ស្រុក, មន្ទីរ-អង្គភាពជុំវិញខេត្ត, ឃុំ-សង្កាត់ និងស្ថាប័នពាក់ព័ន្ធដទៃទៀត ព្រមទាំងបងប្អូនប្រជាពលរដ្ឋក្នុងខេត្តកំពង់ចាម ដូចខាងក្រោម ៖

១- រដ្ឋបាលក្រុង-ស្រុក ឃុំ-សង្កាត់ ត្រូវបន្តធ្វើការអប់រំផ្សព្វផ្សាយ ណែនាំ និងត្រួតពិនិត្យតាមដានឱ្យបានជាប់ជាប្រចាំនូវការអនុវត្តវិធានការសុខាភិបាល ដើម្បីការពារជំងឺកូវីដ-១៩ នៅតាមមូលដ្ឋាន។

២- គណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង-ស្រុក និងឃុំ-សង្កាត់ ត្រូវបន្តក្តាប់មុខសញ្ញាចំណូលស្រុកមកពីតំបន់មានហានិភ័យខ្ពស់ តម្រូវឱ្យអនុវត្តវិធានចត្តាឡីស័ករយៈពេល១៤ថ្ងៃជាកំហិតនៅមណ្ឌលចត្តាឡីស័ករបស់រដ្ឋបាលស្រុក។

៣- គណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង-ស្រុក បន្តពង្រឹងគោលដៅអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ៤៤សសរ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២១ ស្តីពីការហាមឃាត់ការធ្វើដំណើរ និងការបិទរមណីយដ្ឋានទេសចរណ៍ នៅទូទាំងប្រទេសជាបណ្តោះអាសន្ន ដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលនៃជម្ងឺកូវីដ-១៩ និងទប់ស្កាត់ការលួចឆ្លងកាត់តាមគ្រប់រូបភាព សំដៅធ្វើយ៉ាងណា មិនឱ្យមានលំហូរប្រជាពលរដ្ឋពីតំបន់ដែលមានហានិភ័យខ្ពស់ ចូលមកក្នុងភូមិសាស្ត្រខេត្តកំពង់ចាម។

៤- មន្ទីរពាណិជ្ជកម្មខេត្ត និងមន្ទីរទេសចរណ៍ខេត្ត ត្រូវសហការជាមួយរដ្ឋបាលក្រុង-ស្រុក ចុះត្រួតពិនិត្យការអនុវត្តរបស់បងប្អូនអាជីវករលក់ដូរនៅក្នុងផ្សារ ផ្សារទំនើប ម៉ាត ភោជនីយដ្ឋាន អាហារដ្ឋាន តូបអាហារ តូបលក់តែវ៉ាន់ ហាងកាហ្វេ ហាងភេសជ្ជៈ ដេប៉ូចែកចាយស្រាបៀរគ្រប់ប្រភេទ និងអាជីវកម្មផ្នែកអាហារ-គ្រឿងស្រវឹងគ្រប់ប្រភេទ។ ក្នុងករណីរកឃើញថា ម្ចាស់អាជីវកម្មណាមួយដែលមិនព្រមអនុវត្ត ឬអនុវត្តផ្ទុយពីខ្លឹមសារនៃសេចក្តីណែនាំនេះ ត្រូវអនុវត្តវិធានរដ្ឋបាល និងវិធានការច្បាប់ដោយគ្មានការលើកលែងឡើយ។

៥- គណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង-ស្រុក មន្ទីរ-អង្គភាពជុំវិញខេត្ត និងឃុំ-សង្កាត់ ត្រូវបន្តអនុវត្តឱ្យបានម៉ឺងម៉ាត់នូវវិធានការរដ្ឋបាល ដែលរដ្ឋបាលខេត្តដាក់ចេញដូចខាងក្រោម៖

**ក-ត្រូវបន្តផ្អាកជាបណ្តោះអាសន្ននូវ៖**

- ទីតាំងដេប៉ូចែកចាយស្រាបៀរគ្រប់ប្រភេទ អាហារដ្ឋាន និងកន្លែងដែលមានលក់គ្រឿងស្រវឹងគ្រប់ប្រភេទ នៅក្នុងភូមិសាស្ត្ររបស់ខ្លួន រហូតដល់ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២១។
- ទីតាំងរមណីយដ្ឋានទេសចរណ៍ធម្មជាតិ និងកែច្នៃទូទាំងខេត្ត ចាប់ពីថ្ងៃទី២១ ខែមេសា ដល់ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២១។
- សកម្មភាពអាជីវកម្មពេលរាត្រី រួមមាន៖ ភោជនីយដ្ឋាន អាហារដ្ឋាន តូបលក់ចល័ត ផ្សារទំនើប ម៉ាត ហាងលក់ទំនិញគ្រប់ប្រភេទ ការជួបជុំនៅតាមទីសាធារណៈនានាដែលមានសភាពអ៊ូអរ និងមានមនុស្សជួបជុំក្នុងចំនួនច្រើន ត្រូវផ្អាកជាបណ្តោះអាសន្ន ចាប់ពីម៉ោង២០.០០នាទី ដល់ម៉ោង ០៥.០០នាទីព្រឹកជាកំហិត ចាប់ពីថ្ងៃទី២១ ខែមេសា ដល់ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២១។
- រាល់សកម្មភាពកីឡា និងការប្រមូលផ្តុំមនុស្សច្រើន ក្នុងគោលបំណងប្រារព្ធពិធីជប់លៀងកម្សាន្តសប្បាយនានានៅតាមគេហដ្ឋាន កន្លែងធ្វើការ និងក្រុមហ៊ុនឯកជន។

**ខ-ត្រូវបានលើកលែងនូវ៖**

- ការជួបជុំលក្ខណៈសមាជិកគ្រួសារដែលរស់នៅក្នុងលំនៅដ្ឋានជាមួយគ្នា និងការរៀបចំពិធីបុណ្យសព ដោយត្រូវកម្រិតមិនឱ្យមានការជួបជុំមនុស្ស ក្នុងទ្រង់ទ្រាយធំ និងអនុវត្តគោរពយ៉ាងម៉ឺងម៉ាត់នូវវិធានការអនាម័យរបស់ក្រសួងសុខាភិបាល និងតាមការកំណត់របស់អាជ្ញាធរមូលដ្ឋាន។
- ការជួបជុំរបស់បុគ្គលិកសុខាភិបាល និងអាជ្ញាធរមានសមត្ថកិច្ចដែលកំពុងបំពេញភារកិច្ចសង្គ្រោះបន្ទាន់ យកវត្ថុសំណាកទៅវិភាគរកមេរោគកូវីដ-១៩ ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ និងរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ។

- ការជួបជុំមនុស្សដើម្បីផ្តល់ជំនួយចាំបាច់នានាដល់ជនងាយរងគ្រោះ ឬជនរងគ្រោះ និងសកម្មភាពបម្រើផលប្រយោជន៍សាធារណៈ ឬក្នុងគោលបំណងផ្សេងទៀតតាមការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ច។
- ការជួបជុំមនុស្សក្នុងអំឡុងពេលនៃកិច្ចនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌ ឬរបស់សាលាជម្រះក្តី។
- សេវាដឹកជញ្ជូនគ្រឿងឧបភោគបរិភោគប្រចាំថ្ងៃ

ទទួលបានការណែនាំខាងលើ សូមលោកអភិបាលនៃគណៈអភិបាលក្រុង-ស្រុក លោក-លោកស្រីប្រធានមន្ទីរ-អង្គភាពជុំវិញខេត្ត មេឃុំ-ចៅសង្កាត់ ស្ថាប័នពាក់ព័ន្ធដទៃទៀត និងបងប្អូនប្រជាពលរដ្ឋ ត្រូវចូលរួមជាមួយរដ្ឋបាលខេត្តកំពង់ចាម អនុវត្តឱ្យបានម៉ឺងម៉ាត់ និងខ្ជាប់ខ្ជួននូវវិធានការសុខាភិបាល ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងត្រូវប្រកាន់ខ្ជាប់នូវវិធានការ «**៣កុំ ៣ការពារ**» ដើម្បីការពារក្រុមគ្រួសារ និងសហគមន៍ឱ្យជៀសផុតពីជំងឺដ៏មហាប្រល័យនេះ និងសូមហាមឃាត់បងប្អូនប្រជាពលរដ្ឋក្នុងខេត្ត មិនឱ្យមានជួបជុំប្រមូលផ្តុំមនុស្សច្រើន និងមិនត្រូវចេញទៅក្រៅផ្ទះប្រសិនបើមិនមានករណីចាំបាច់។ សូមផ្អាកនូវរាល់ការធ្វើដំណើរឆ្លងពីខេត្តមួយទៅខេត្តមួយទៀត ពិសេសការចេញ-ចូលតំបន់ដែលបិទខ្ទប់ដែលបានកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា៕

ថ្ងៃពុធ ១០កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤

កំពង់ចាម ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២១

**អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម**

អ៊ុន ចាន់ដា

__កន្លែងទទួល៖__

-ក្រសួងមហាផ្ទៃ

-ក្រសួងសុខាភិបាល

-ខុទ្ទកាល័យឯកឧត្តមឧនាយករដ្ឋមន្ត្រី យឹម ឆៃលី

«*__ដើម្បីគោរពជូនជ្រាប__*»

-រដ្ឋបាលក្រុង-ស្រុក

-មន្ទីរ-អង្គភាពជុំវិញខេត្ត

-រដ្ឋបាលឃុំ-សង្កាត់

«*__ដើម្បីមុខការ__*»

-គ្រប់បណ្តាញសារព័ត៌មាន

«*__ដើម្បីសហការផ្សព្វផ្សាយ__*»

-ឯកសារ